សេចក្តីប្រកាសសារពត៌មាន | សំរាប់ការចេញផ្សាយបន្ទាន់

# ទឹកឃ្មុំព្រៃមណ្ឌលគីរីជានិមិត្តរូបនៃឆន្ទៈសហគមន៍មូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានក្នុងព្រៃប្រកបដោយនិរន្តរភាព

ទីក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៩ - ក្រោមអធិបតីភាពរបស់ ឯកឧត្តម កែវ ហ៊ិន អភិបាលខេត្តមណ្ឌលគីរី ព្រមទាំងវត្តមាននៃអាជ្ញាធរថ្នាក់ខេត្តដទៃទៀតជាច្រើន សហគមន៍ជនជាតិភាគតិចព្នងនៃឃុំក្រង់តេះ និងឃុំពូជ្រៃ បានប្រារព្ធពិធីសម្ពោធ និង ឃោសនាផលិតផលទឹកឃ្មុំព្រៃមណ្ឌលគីរី ថ្មីសុទ្ធពីធម្មជាតិ ដើម្បីបង្ហាញអំពីឆន្ទៈក្នុងការចូលរួមការពារធនធាននៅក្នុងព្រៃ ព្រមទាំងការលើក ស្ទួយការអភិវឌ្ឍន៍ការចិញ្ចឹមរបស់ពួកគេដោយផ្អែកលើអនុផលព្រៃឈើជាមូលដ្ឋានមួយសំខាន់ ។

ផលិតផលទឹកឃ្មុំព្រៃមណ្ឌលគីរីជាលទ្ធផលស្តែងចេញពីគំរោងអភិវឌ្ឍន៍ការចិញ្ចឹមជីវិតផ្អែកលើអនុផលព្រៃឈើមួយ ដែលពួកគេបានអនុវត្ត ចាប់តាំងពីឆ្នាំ២០០៧មក ដោយក្នុងនោះក្រុមអ្នកប្រមូលផលឃ្មុំនៃសហគមន៍ទាំងពីរ មានឈ្មោះ ក្រង់វ៉ាទូន និង ព្រៃរ៉ូដង់ បានដំណើរការ និងគ្រប់គ្រងការផលិតទឹកឃ្មុំរៀងៗខ្លួន ដើម្បីលើកដំកើងតំលៃនៃធនធាននៅក្នុងព្រៃជាមធ្យោបាយមួយសំខាន់ក្នុងការជួយជំរុញអោយ ជីវភាពរស់នៅរបស់ពួកគេមានភាពប្រសើរឡើង ។ សមិទ្ធិផលនេះក៏បង្ហាញអោយឃើញផងដែរនូវការយល់ដឹងប្រសើរជាងមុនរបស់ប្រជាជន មូលដ្ឋានអំពីសារៈសំខាន់ជាមូលដ្ឋានគ្រឹះនៃ តួនាទី និងការចូលរួមរបស់ពួកគេក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ ដើម្បីការពារ និងថែរក្សា សម្បត្តិព្រៃឈើ និងសត្វព្រៃដែលមាននៅជុំវិញតំបន់ពួកគេកំពុងរស់នៅ ។

លោក សេង ទៀក នាយកអង្គការ WWF បានមានប្រសាសន៍ថា៖ ”អង្គការ WWF ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ជាដៃគូបាននិងកំពុងធ្វើការយ៉ាងសកម្មជាមួយសហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់ទេសភាពព្រៃភាគខាងកើត ក្នុងខេត្តមណ្ឌលគីរី ក្នុងការជួយ លើកទឹកចិត្តពួកគេអោយចូលរួមក្នុងសកម្មភាពការងារអភិរក្ស ហើយទន្ទឹមនឹងនោះក៏ជួយស្វែងរកឱកាសថ្មីៗដើម្បីអោយការ ចិញ្ចឹមជីវិតរបស់ពួកគេកាន់តែប្រសើរឡើង ។”

ទឹកឃ្មុំជាប្រភេទអនុផលព្រៃឈើមួយបែបដែលប្រជាជនមូលដ្ឋានរស់នៅក្នុង និងជុំវិញតំបន់ការពារក្នុងខេត្តមណ្ឌលគីរីពឹងអាស្រ័យសំរាប់ ផ្គត់ផ្គង់ការចិញ្ចឹមជីវិត ។ ការជំរុញអោយសហគមន៍ចេះប្រមូលទឹកឃ្មុំដោយនិរន្តរភាពនិងចេះធ្វើការកែច្នៃផលិតផលទឹកឃ្មុំប្រកបដោយ គុណភាពនិងអនាម័យខ្ពស់គឺជាការបង្ហាញពីគុណតំលៃនៃទំនាក់ទំនងរវាងមនុស្ស ព្រៃឈើ និងអនុផលព្រៃឈើ ។

អ្នកស្រី អេមី មាលីង ទីប្រឹក្សាបច្ចេកទេសផ្នែកការងារផ្សព្វផ្សាយសហគមន៍នៃអង្គការ WWF បាននិយាយថា៖ ”អង្គការ WWF ធ្វើការ ជាមួយអង្គការ NTFP-EP និងមន្ទីរពាក់ព័ន្ធក្នុងខេត្តដើម្បីជួយលើកស្ទួយ និងគាំទ្រសកម្មភាពរបស់សហគមន៍ក្នុងការកែច្នៃអនុផលព្រៃឈើ ជាផលិតផល តាមរយៈការជួយចងក្រង សហគមន៍ជាក្រុមឧទាហរណ៍ដូចជាក្រុមអ្នកប្រមូលផលឃ្មុំ ការផ្តល់វគ្គបំពាក់បំប៉នលើផ្នែក

បច្ចេកទេសពាក់ព័ន្ធនឹងការកែច្នៃនិងជំនាញផ្សេងៗទៀត ការនាំអោយពួកគាត់ចូលរួមក្នុងដំណើរការនៃការគ្រប់គ្រងធនធានព្រៃឈើ និងជួយធ្វើការផ្សព្វផ្សាយដល់សាធារណៈជនអំពីសមិទ្ធិផល ដែលពួកគេសំរេចបាន ។"

ទឹកឃ្មុំដែលផលិតឡើងដោយប្រភេទសត្វឃ្មុំព្រៃរស់នៅក្នុងតំបន់ការពារ និងក្នុងតំបន់ព្រៃការពារសហគមន៏ មានសក្តានុពលក្នុងការទាក់ទាញទីផ្សារក្នុងស្រុក និងអន្តរជាតិ ប្រសិនបើផលិតទឹកឃ្មុំឆ្លើយតបទៅនឹងល័ក្ខខ័ណ្ឌតំរូវតាមស្តង់ដាអន្តរជាតិ ពោលគឺគុណភាព បរិមាណ តំលៃ ការវេចខ្ចប់ និងការប្រើប្រាស់ផលិតផលជាដើម ។ ដើម្បីធានាថាការប្រមូលផលទឹកឃ្មុំព្រៃជាមធ្យោបាយចិញ្ចឹមជីវិតដោយនិរន្តរភាព សហគមន៏មូលដ្ឋានធ្វើការប្រមូលទឹកឃ្មុំដោយអនុវត្តតាមវិធីសាស្រ្តបច្ចេកទេសត្រឹមត្រូវ ធ្វើការកែច្នៃជាផលិតផលទឹកឃ្មុំស្របតាមស្តង់ដា និងបទដ្ឋានអនាម័យត្រឹមត្រូវ ព្រមទាំងធ្វើការវេចខ្ចប់ដោយមានឈ្មោះ និងផ្លាកសញ្ញាសំគាល់ផលិតផលទៀតផង ។

កញ្ញា ហ្វេមី ពីនតូ អ្នកសំរបសំរួលនៅអង្គការ NTFP-EP កម្ពុជា បាននិយាយថាៈ"បើទោះបីជាផលិតផលទឹកឃ្មុំមានទីផ្សារធំនៅកម្ពុជា ក៏ប៉ុន្តែផលិតផលទឹកឃ្មុំព្រៃមណ្ឌលគីរីនៅមិនទាន់បានផ្សព្វផ្សាយអោយអតិថិជនបានដឹងគ្រប់គ្នានៅឡើយ ។ ផលិតផលនេះនឹងមានលទ្ធភាពប្រកួតប្រជែងជាមួយផលិតផលទឹកឃ្មុំដទៃទៀតនៅក្នុងទីផ្សារ ប្រសិនបើការប្រមូលផលទឹកឃ្មុំពីព្រៃមានលក្ខណៈនិរន្ត ហើយជាផលិតផលមានគុណភាពខ្ពស់ ។"

ហ្វេមីបានបន្ថែមទៀតថាៈ"កិច្ចខិតខំប្រឹងប្រែងរបស់យើងត្រូវបានគាំទ្រដោយទំនាក់ទំនង និងកិច្ចសហការណ៏ល្អពីសំណាក់បណ្តាស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ព្រមទាំងសមាជិកសហគមន៏មូលដ្ឋាន ។"

ការប្រារព្ធពិធីសម្ពោធផលិតផលទឹកឃ្មុំព្រៃមណ្ឌលគីរីត្រូវបានរៀបចំឡើងស្របពេលជាមួយនឹងយុទ្ធនាការឃោសនាបណ្តាញការងារសហគមន៏ និងការផ្សព្វផ្សាយដើម្បីពង្រីកទីផ្សារសំរាប់ផលិតជាស្នាដៃរបស់សហគមន៏មូលដ្ឋាន ដែលធ្វើឡើងនៅកន្លែងផ្សេងទៀតដូចជា នៅទីក្រុងភ្នំពេញ ខេត្តរតនៈគីរី និងនៅខេត្តសៀមរាបនិងខេត្តកោះកុងសំរាប់ថ្ងៃខាងមុខទៀត ក្នុងគោលបំណងលើកទឹកចិត្តសហគមន៏ ក៏ដូចជាលើកស្ទួយការកែច្នៃអនុផលព្រៃឈើជាផលិតផលរបស់ពួកគេ ។

**សំរាប់ពត៏មានបន្ថែម** សូមផ្ញើរសំណួរទៅកាន់អាស័យដ្ឋានអ៊ីម៉ែលនេះ asnarith.tep@wwfgreatermekong.org ឬ តាមទូរស័ព្ទលេខ ០២៣ ២១៨ ០៣៤ ។

**ពត៏មានជំនួយដល់ការនិពន្ធ**

- នៅក្នុងពិធីសម្ពោធផលិតទឹកឃ្មុំព្រៃមណ្ឌលគីរីនាទីក្រុងសែនមនោរម្យមានការចូលរួមយ៉ាងកុះករពីសំណាក់មន្ត្រីរបស់រាជរដ្ឋាភិបាលថ្នាក់ ជាតិ អ្នកតំណាងស្ថាប័នមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អ្នកសារពត៌មាន ប្រជាពលរដ្ឋដែលរស់នៅទីក្រុងសែនមនោរម្យ និងមកពី តាមបណ្តាភូមិ/ឃុំនានាសរុបចំនួនប្រហែល ១០០ នាក់ ។ កម្មវិធីសំរាប់ពីថ្ងៃទី៧ដល់ទី៩រួមមាន១/ពិធីសម្ពោធផលិតផល

ជាផ្លូវការក្រោមអធិបតីភាពរបស់ឯកឧត្តម កែវ ហ៊ាន អភិបាលខេត្តមណ្ឌលគិរី អ្នកតំណាងមកពីនាយកដ្ឋានពាណិជ្ជកម្មខេត្ត តំណាងសហគមន៍មូលដ្ឋាន ២/ការធ្វើបទបង្ហាញអំពីផលិតផលទឹកឃ្មុំ និងពិធីភ្លក់រស់ជាតិទឹកឃ្មុំ ៣/កិច្ចសន្ទនារវាងសមាជិកសហគមន៍ និងអាជ្ញាធរមូលដ្ឋានអំពីគោលបំណងថែរក្សាតំបន់ព្រៃដែលសត្វឃ្មុំរស់នៅសំរាប់ជាប្រយោជន៏ដល់ការកែច្នៃជាផលិតផលទឹកឃ្មុំ ព្រមទាំង៤/ការបង្ហាញអំពីសកម្មភាពនិងបច្ចេកទេសក្នុងការប្រមូលផលទឹកឃ្មុំពីព្រៃដោយប្រជាជនសហគមន៍ក្រង់តេះ ។

- អង្គការ WWF ធ្វើការសហការណ៏ជាមួយស្ថាប័នរាជរដ្ឋាភិបាល សហគមន៏មូលដ្ឋាន និងបណ្តាញការងារអនុផលព្រៃឈើ នៅក្នុងតំបន់ទេសភាពព្រៃភាគខាងកើតនៃកម្ពុជា និងនៅក្នុងខេត្តកំពត ដើម្បីធ្វើការអភិវឌ្ឍន៏ការចិញ្ចឹមជីវិតសហគមន៏មូលដ្ឋាន ដោយផ្អែកលើអនុផលព្រៃឈើ ។ អង្គការ WWF មានគោលដៅថែរក្សានូវប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងធ្វើការបំផុសបន្ថែមការប្រើប្រាស់នូវធនធានធម្មជាតិប្រកបដោយនិរន្តរភាពសំរាប់ដល់កូនចៅជំនាន់ក្រោយៗទៀត ។
- គំរោងតំបន់ព្រៃទេសភាពភាគខាងកើតនៃអង្គការ WWF ធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៏មូលដ្ឋានលើការអភិរក្សតំបន់ទេសភាពព្រៃល្បោះ និងប្រភេទសត្វព្រៃដែលមានតម្លៃជាសាកលជាច្រើននៅក្នុងប្រទេសកម្ពុជា។ គំរោងនេះផ្តោតលើការងារគ្រប់គ្រង និង ការពារតំបន់អភិរក្សចំនួនពីរគឺ **ព្រៃការពារមណ្ឌលគីរី** និង **ដែនជម្រកសត្វព្រៃភ្នំព្រេច** ដែលតំបន់ទាំងពីរនេះមានផ្ទៃក្រលាសរុប ៥៨៥.៦៧៧ ហិកតា ។ គំរោងមានទិសដៅថែរក្សា និងការពារតំបន់ទេសភាពព្រៃល្បោះកម្ពុជាដែលនៅសេសសល់ចុងក្រោយនេះអោយមានសភាពល្អនិងតភ្ជាប់គ្នា ហើយជួយប្រជាជនក្នុងការការពារធនធានសត្វព្រៃ ព្រមទាំងលើកកំពស់ការចិញ្ចឹមជីវិតរបស់ពួកគេប្រកបដោយនិរន្តរភាព ។
- បេសកកម្មរបស់អង្គការ WWF កម្ពុជា គឺធានាអោយមានការចូលរួម និងគាំទ្រយ៉ាងពេញទំហឹងពីសំណាក់មនុស្សគ្រប់រូប ដើម្បីធ្វើការអភិរក្សជីវចម្រុះដ៏សំបូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF កម្ពុជា នឹងជំរុញអោយមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៏ដល់មនុស្សគ្រប់រូប ក៏ដូចជាការធ្វើអោយប្រសើរឡើងនូវក៏រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមជាវិភាគទានដល់ការកាត់បន្ថយភាពក្រីក្រនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការលើកទឹកចិត្តអោយមាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។
- នៅកម្ពុជា អង្គការ NTFP-EP ធ្វើការជាមួយបណ្តាញការងារអនុផលព្រៃឈើក្នុងការគាំទ្រការធ្វើអោយប្រសើរឡើងនូវការចិញ្ចឹមជីវិតរបស់សហគមន៏មូលដ្ឋានដោយផ្អែកលើអនុផលព្រៃឈើ នៅក្នុងខេត្តចំនួន៨ ក្នុងចំណោមនោះមានមណ្ឌលគីរី និងរតនៈគីរី តាមរយៈការផ្តល់នូវការកសាងសមត្ថភាព និងការផ្តល់ប្រឹក្សាបច្ចេកទេស ។